មាតិកា

១. មេរៀនទី១: ការគណនាធ្នឹមបេតុងអាមេ (RC Beam Design)……1

1. ការកំណត់ Beam Definition និង Beam Section ……6
2. ការកកំណត់ប្រហោងរបស់ធ្នឹមដើម្បីដាក់ខ្សែភ្លើង ឬ ទុយោ (Beam opening)……9
3. ការកំណត់ការដាក់បន្ទុកលើធ្នឹម (Beam Loads)……..10
4. ការកំណត់ Story Parameters ……13
5. ការកំណត់ Calculation Option ……13
6. ការកំណត់ Reinforcement Patterns ……15
7. ចាប់ផ្តើមគណនារកសៃដែក Start Calculation……..18
8. ការត្រួតពិនិត្យមើលការដាក់រៀបចំសៃដែក Beam- Reinforcement ……22
9. កំណត់សំគាល់ការគណនា Calculation Note ……23
10. Drawing Parameter ……..23
11. មើលប្លង់ Drawings ……25

២. មេរៀនទី២: ការគណនាកម្រាលខណ្ឌ (RC slab design) ……26

1. ការកំណត់ Code Units and Formats ……...29
2. កំណត់ Materials ត្រូវយកកូដ Euro – Code ……..30
3. កំណត់ Steel ……...30
4. កំណត់ Concrete ……30
5. កំណត់ Database for reinforcement ……31
6. កំណត់ Design Code ……..32
7. កំណត់ Load ក្នុងប្រអប់ Load Combination ……32

I. ការកំណត់ការគូសកម្រាលខណ្ឌ ……33

II. ការកំណត់កំរាស់កម្រាលខណ្ឌ Slab thickness ……...34

III. ការកំណត់ទំរ និង ការដាក់បន្ទុក Determine supported ……....38

IV. ការបង្កើតប្រភេទបន្ទុក Load Types ……..39

VI. កំណត់ការដាក់បន្ទុកលើកម្រាលខណ្ឌ Apply Loads ……...39

VII. ការបន្សំបន្ទុក Combination Loads ……..……42

VIII. ការ Mesh កម្រាលខណ្ឌ ……45

IX. ការគណនាកម្រាលខណ្ឌ ……47

X. ការគណនាសសៃដែក ……50

មេរៀនទី៣: ការគណនាសសរ RC Column Design ……64

I. ការកំណត់ Tools ……..67

1. ការកំណត់ Units and Formats ……67
2. ការកំណត់ Materials ……..68
3. ការកំណត់ Steel….. ……...68
4. ការកំនត់ Concrete ……68
5. ការជ្រើសរើស Database ……69
6. កំណត់ Design code ……..70
7. ការកំណត់ Load ក្នុងប្រអប់ Code combination ……70

មេរៀនទី៤: ការគណនាគ្រឹះរាក់ Shallow Foundation Design ……84

I. កំណត់ Job Preperence …….....87

1. ការកំណត់ Units and Formats ……..87

2. កំណត់ Code Materials ……88

3. កំណត់ Tab steel ……88

4. កំណត់ Tab Concrete ……..88

5. កំណត់ Database ……89

6. កំណត់ Load ក្នុងប្រអប់ Code Combinations ……90

II. ការកំណត់ទំហំគ្រឹះ សសរ និង ប្រភេទគ្រឹះ Foundation Definition……..91

1. ការកំណត់ទំហំជើងតាង និង សសរត្បឺ ……91

2. ការកំណត់ទំហំសសរ Tab Pier …….. 91

III. ការកំណត់ស្រទាប់ដីនៅក្រោមគ្រឹះ Foundation Soil ……..92

1. ជ្រើសរើស Icon Foundation soil ……92

2. ជ្រើសរើសប្រភេទដីបន្ថែម Edit database ……..92

IV. ការកំណត់បន្ទុកដែលមានអំពើមកគ្រឹះ Foundation Loads ……93

1. ជ្រើសរើស Icon Foundation Load ……93

2. ការកំណត់បន្ទុកថេរ Dead Load ……..94

3. ការកំណត់បន្ទុកអថេរ Live Load ……94

V. ការកំណត់ Story Parameter ……95

VI. ការកំណត់ Geotechnical Option ……95

VII. ការកំណត់ Calculation Option ……96

VIII. ការកំណត់ Reinforcement Pattern …….. 98

IX. ការចាប់ផ្តើមគណនារកសរសៃដែក Start Calculation ……99

X. ការត្រួតពិនិត្យមើលការរៀបចំសរសៃដែក Foundation Reinforcement ……..100

www.yerngshare.blogspot.com

XI. Calculation Note ……101
XII. Drawing Parameters ……101
XIII. Drawing ……..102

មេរៀនទី៥: ការគណនាក្នុងបួង 3D ……103

1. ការកំណត់យកអ័កស Axis សំរាប់ការគូរ ……103

1.1 ការកំណត់អ័ក្ស X ……..103

1.2 ការកំនត់អ័ក្ស Y……104

1.3 ការកំនត់អ័ក្ស Z ……105

2. ការគូសធ្នឹម និង សសរ ……..107

2.1 ការបង្កើតមុខកាត់ធ្នឹម ……107

2.2 ការបង្កើតមុខកាត់សសរ ……..108

2.3 ការកំណត់បន្ទុកដែលមានអំពើលើធ្នឹម ……109

មេរៀនទី៦: Truss 2D Design ……122

1. ការកំណត់ Material និង Code សម្រាប់គណនា ……..123

2. ការកំណត់ទំរង់របស់ Truss ……..125

3. ការកំណត់ទំរ Truss ……127

4. ការកំណត់បន្ទុកដែលមានអំពើលើ Truss ……128

4.1 ការកំណត់ប្រភេទបន្ទុក Load Types ……..128

4.2 ការកំណត់តំលៃបន្ទុក ……128

4.3 ការដាក់បន្ទុក DL1 ……..128

4.4 ការដាក់បន្ទុក LL1 ……..129

4.5 ការបន្សំបន្ទុក Load Combination ……..130

www.yerngshare.blogspot.com

5. ការកំណត់រកកំលាំងក្នុងរបាររបស់ Truss ……..131

6. ការត្រួតពិនិត្យ Check ឬ Design មុខកាត់របាររបស់ Truss ……...133

6.1 Member verification ……133

មេរៀនទី៧: 3D Steel Frame ……...134

1. Click Icon Frame 3D Design ……...136

2. ការកំណត់អ័ក្ស Axis សំរាប់គូរ ……...136

2.1 កំណត់អ័ក្ស X ……137

2.2 កំណត់អ័ក្ស Y ……137

2.3 កំណត់អ័កស Z ……137

3. ការគូសសរ និង Steel Frame ……..139

4. ការគូសសរបេតុងអាមេ ……..140

5. ការគូសសរ UPA 160 ……...140

6. ការដាក់ទំរ Support ……141

7. ការគូសធ្នឹម Beam ……141

8. ការថតចំលងរូបភាព Copy Frame ……142

9. ការគូស CAE 40 x 3 ……143

10. គូសរបារដែកដែលមានមុខកាត់ CAE 40 x 3 ……143

11. ការកំណត់បន្ទុកមានអំពើលើធ្នឹម 155


12. Reference ……..156

www.yerngshare.blogspot.com


មេរៀនទី១

ការគណនាធ្នឹមបេតុងអាម៉េ

RC Beam Design




<u>សំគាល់</u> ៖ យើងត្រូវបែងចែកមុំ ៤៥ ដឺក្រេ ទៅលើធ្នឹមដែលយើងត្រូវដាក់បន្ទុកពីលើ ។




Plan View

មុខកាត់គ្រឿងបង្គុំ Frame Section :

- មុខកាត់ធ្នឹមមេ : 30cm x 50cm
- មុខកាត់ធ្នឹមរង : 20cm x 30cm
- មុខកាត់សសរ : 30cm x 30cm
- ការ៉ូ និង បាយអរ : 5cm (Mortar + Tile)
- បង្គប់សេកំរាស់ : 10cm (Slab)
- បាយអរបូកក្រោមបង្គប់សេ : 1.5cm (Plastering)





បន្ទុកមានអំពើមកលើកំរាលខណ្ឌក្នុង 1 m^2 :

- Self - Weight (មិនចាំបាច់កំណត់ទេ ពីព្រោះទុកអោយ Program វាកំណត់ដោយខ្លួនវា)
- Live Load : LL=1.5 kN/m^2
- Dead Load : (Slab + Mortar + Tile + Plastering)

  Slab = 0.1m x 25kN/m^3 = 2.5kN/m^2


  Mortar + Tile + Plastering = (0.05m + 0.015m) x 20kN/m^3 = 1.2kN/m^2
- Total Dead Load : 3.7kN/m^2


Analysis and Design ដោយ : ACI code

Material Properties for Analysis and Design :


- Yield Strength of Longitudinal Reinforcement : 390 MPa
- Yield Strength of Transversal Reinforcement : 235 MPa
- Compressive Strength of Concrete (Cylinder) : 25 MPa

Step by Step Solution

នៅពេលបើក Program Autodesk Robot Structural Analysis Professional 2010 ដំបូងយើងនិងឃើញដូចរូបខាងក្រោមបន្ទាប់មកយើងជ្រើសរើសយក Icon  ដូចដែលបានបង្ហាញនៅលើរូបខាងក្រោម ៖




- បន្ទាប់មកទៀតអេក្រង់នឹងបង្ហាញដូចរូបខាងក្រោមនេះ





- **<u>បន្ទាប់មកចូរកំណត់</u>** <u>Units and Format, Materials and Codes មុនពេលធ្វើការ Analysis and Design :</u>

  - ចុចលើ Tool Menu > Job Preference……




  - អេក្រង់នឹងបង្ហាញផ្ទាំងដូចរូប នៅត្រង់ Units and Formats ត្រូវកំណត់វាជា Metric រួច Yes







- នៅត្រង់ Materials ត្រូវកំណត់កូដអោយ Materials ត្រូវយកកូដ Euro code រួចចុចទៅលើ Modification ដើម្បីកំណត់ ។




- រួចចុចលើ Tab Steel រួចត្រូវបំពេញ Name និង Description ដូចខាងក្រោម




- រួចចុចលើ Tab Concrete រួចត្រូវបំពេញ Name និង Description និង Young modulus ដូចខាងក្រោម រួចចុច OK ។ រួចចុច Database > Reinforcing bars ដើម្បីជ្រើសរើសយក BAEL 99 រួចចុច ok ។






- រួចចុចលើ Design codes ក្នុងប្រអប់ RC Structures ត្រូវកំណត់ជា ACI 318/99 metric



- នៅត្រង់ Loads ក្នុងប្រអប់ Code combinations ត្រូវកំណត់ជា LRFD រួចចុច OK ។



បន្ទាប់មកចុច Save job Preference រួចចុច File name : ACI Code (Save as type : job Preference) រួចចុច Save , ok , Close . ។

១- **ការកំណត់** Beam - Definition **និង** Beam - Sections

១.១- កំណត់ធ្នឹមទី១ដែលមានប្រលោះ 8m


១.១.១- ការកំណត់មុខកាត់

1- Select លើធ្នឹមដែលចង់កំណត់មុខកាត់


2- ចុចលើរូប  ដើម្បីកំណត់មុខកាត់ធ្នឹមរាងចតុកោណកែង

3- នៅក្នុងប្រអប់ Basic dimensions វាយតំលៃ b=30cm, h=50cm

4- រួចចុច Apply



១.១.២- ការកំណត់ប្រវែងរបស់ធ្នឹម និង ប្រភេទទំរ



1 -ចុចលើ Span Geometry

2 -នៅក្នុងប្រអប់ Length វាយតំលៃ 3.7m


3 -នៅ Left Support វាយតំលៃនៅក្នុងប្រអប់ Width=0.3m សំរាប់មុខកាត់ទំរខាងឆ្វេង

4 -នៅ Right Support វាយតំលៃនៅក្នុងប្រអប់ Width=0.3m សំរាប់មុខកាត់ទំរខាងស្តាំ


5- រួចចុច Apply

១.២- បន្ទាប់មកកំណត់ធ្នឹមទី២ និង ទី៣ ដែលមានប្រលោះ 8m និង 6m

- ដំបូងយើងធ្វើការ Copy ធ្នឹមទី១ ដែលបានកំណត់ហើយ ដោយបំពេញតំលៃ 2 នៅត្រង់ Copy Span នៅក្នុងប្រអប់ Beam Geometry រួចចុច Copy Span




- រួចនិងទទួលបានរូបដូចខាងក្រោម



- ដោយសារប្រវែងប្រលោះដែលបាន Copy មិនដូចក្នុងប្រធាន ដូច្នេះយើងត្រូវកែតំរូវវាឡើងវិញដោយចុច Select ចុចលើធ្នឹមនីមួយៗ ជាមុនសិនទើបយើងកែ ។ ប៉ុន្តែយើងកែតែប្រវែងប្រលោះរបស់ធ្នឹមប៉ុណ្ណោះ ពីព្រោះធ្នឹមទាំងអស់មានមុខកាត់ដូចគ្នា ។

១.៣- ការកែតំរូវប្រវែងប្រលោះរបស់ធ្នឹម


- ចុចលើធ្នឹមទី ២ គឺឈ្មោះ P2 បន្ទាប់មកធ្វើការកែប្រវែងប្រលោះរបស់ធ្នឹម នៅក្នុងផ្ទាំង Dimension Definition ត្រង់ Span Geometry ក្នុងប្រលោះ Length វាយលេខ 7.7m ចូលដូចរូបរួច Apply



- រីឯធ្នឹមទី ៣ គឺឈ្មោះ P3 យើងអនុវត្តន៍ដូចទៅនឹងធ្នឹមទី ២ ដែលបានកែរួចហើយនៅខាងលើ ។

១.៤- ធ្វើការកំណត់ធ្នឹម Cantilever ឆ្វេង (1.5m) និង ស្តាំ (1.5m)

- ដោយចុចលើផ្ទាំង Dimension Definition ត្រង់ Beam Geometry រួច Tick យក Left និង Right ត្រង់ Cantilever រួចចុច Apply




- រួចកំណត់ប្រវែង Cantilever

1 - Select Cantilever ឆ្វេងដោយប្រើ Mouse

វាយតំលៃ 1.35m នៅក្នុងប្រអប់ Length រួចចុច Apply

2 - Select Cantilever ស្តាំ ដោយប្រើ Mouse

វាយតំលៃ 1.35m នៅក្នុងប្រអប់ Length រួចចុច Apply



២ - ការកំណត់ប្រហោងរបស់ធ្នឹមដើម្បីដាក់សំរាប់ដាក់ខ្សែភ្លើង ឬ ទុយោ Beam – Opening

ការកំណត់ធ្នឹមរងនៅប្រលោះ 8m ធ្នឹមទី ៣ គឺ P3


- មុនដំបូងត្រូវ Select ធ្នឹម P3 សិនរួចចុច Icon  នេះនៅស្តាំអេក្រង់ រឺ ចុចលើ Layout


1- ក្នុងប្រអប់ Span number វាយលេខ 3
មានន័យថាដាក់ធ្នឹមរងត្រង់ធ្នឹមទី ៣

2- ក្នុងប្រអប់ X Load (m) វាយ 3.85m
និងក្នុងប្រអប់ Y Load (m) វាយ 0.35m

3- ត្រង់ Type Tick យក Adjoining beam
ហើយក្នុងប្រអប់ Lx (m) វាយ 0.2m
និងក្នុងប្រអប់ Lz (m) វាយ 0.3m
មានន័យថា b=20cm និង h=30cm

4- រួចចុច Add





៣- ការកំណត់ការដាក់បន្ទុកលើធ្នឹម Beam – Loads


- ធ្នឹម P1 : DL=3.7kN/m^2 x 1.5m x 2 = 11.1kN/m
  LL=1.5kN/m^2 x 1.5m x 2 = 4.5kN/m
- ធ្នឹម P2 : DL=3.7kN/m^2 x 2m x 2 = 14.8kN/m
  LL=1.5kN/m^2 x 2m x 2 = 6kN/m
- ធ្នឹម P3 : DL=3.7kN/m^2 x 2m x 2 = 14.8kN/m
  LL=1.5kN/m^2 x 2m x 2 = 6kN/m
- ធ្នឹម P4 : DL=3.7kN/m^2 x 2m x 2 = 14.8N/m
  LL=1.5kN/m^2 x 2m x 2 = 6kN/m
- ធ្នឹម P5 : DL=3.7kN/m^2 x 1.5m x 2 = 11.1kN/m
  LL=1.5kN/m^2 x 1.5m x 2 = 4.5kN/m
- ការដាក់បន្ទុកលើធ្នឹមរង DL=25kN/m^3 x 4m x 0.2m x 0.3m = 6kN
  LL=1.5kN/m^2 x 4m x 0.2m = 1.2kN




៣.១- ការដាក់បន្ទុកលើធ្នឹម :

- ដំបូងចុចលើ Icon  នេះនៅស្តាំអេក្រង់ រឺចុចលើ Layout


៣.១.១-ការដាក់បន្ទុកលើធ្នឹម Cantilever ឆ្វេងនៅប្រលោះទី១ គឺ P1 រួចចុច Add




៣.១.២-ការដាក់បន្ទុកលើធ្នឹម Cantilever ស្តាំនៅប្រលោះទី៥ គឺ P5 រួចចុច Add




៣.១.៣-ការដាក់បន្ទុកលើធ្នឹម នៅប្រលោះទី៣ គឺ P3 រួចចុច Add




៣.១.៤-ការដាក់បន្ទុកលើធ្នឹម នៅប្រលោះទី៤ គឺ P4 រួចចុច Add




៣.១.៥-ការដាក់បន្ទុកលើធ្នឹម នៅប្រលោះទី២ គឺ P2 រួចចុច Add



៣.១.៥-ការដាក់បន្ទុកលើធ្នឹមរង នៅប្រលោះទី៣ គឺ P3 រួចចុច Tick នៅត្រង់ Suspended រួចចុច Add




- នៅពេលដាក់បន្ទុករួចហើយអេក្រង់នឹងបង្ហាញដូចរូបខាងក្រោម :



៤- ការកំណត់ Story Parameters

- ដំបូងចុចលើ Icon  នេះនៅស្តាំអេក្រង់ រឺចុចលើ Analysis Menu > Story Parameters រួចចុច OK





៥- ការកំណត់ Calculation Options


នៅក្នុង Calculation Options មាន ៤ Tab ដែលត្រូវកំណត់ :


- Tab General : កំណត់ស្រទាប់ការពារ ផ្ទៀងផ្ទាត់ភាពដាប និង ការកំណត់ផ្សេងទៀត.....
- Tab Concrete : កំណត់រេស៊ីស្តង់សង្កត់របស់បេតុងនៅអាយុ ២៨ ថ្ងៃ
- Tab Longitudinal reinf.. កំណត់រេស៊ីស្តង់ដែកបណ្តោយ និងអង្កត់ផ្ចិត
- Tab Traversal reinf.. កំណត់រេស៊ីស្តង់ដែកកង និងអង្កត់ផ្ចិត
- ដំបូងចុចលើ Icon  នេះនៅស្តាំអេក្រង់ រឺចុចលើ Analysis Menu > Calculation Options រួចចុច OK

Tab General :












Tab Concrete :




Tab Longitudinal reinf…:



Tab Traversal reinf..



- នៅពេលកំណត់រួចរាល់ហើយ ចុចលើ Save As ….. វាយឈ្មោះ Euro code 1 រួចចុច ok ដើម្បីរក្សាទុក ។




៦ - ការកំណត់ Reinforcement Pattern


នៅក្នុង Reinforcement Pattern មាន ៦ Tab ដែលត្រូវកំណត់ :

- Tab General : កំណត់ការដាក់ដែកកង Segment គំលាតពីសសៃដែក១ ទៅសសៃដែក ១.....
- Tab Bottom Reinf : កំណត់ការដាក់សសៃដែកបណ្តោយខាងក្រោមធ្នឹម និងការបង្កប់ដែក
- Tab Top Reinf : កំណត់ការដាក់សសៃដែកបណ្តោយខាងលើធ្នឹម
- Tab Transversal Reinf : កំណត់ការដាក់ដែកកងទាំងនៅកណ្តាលប្រលោះ ត្រង់ទំរ និងធ្នឹមរង
- Tab Constr Reinf : កំណត់ការដាក់សសៃដែកបណ្តោយដែលមិនធ្វើការ និងការតដែក
- Tab Shapes : កំណត់ទ្រង់ទ្រាយនៃការពត់ដែក
-


- ដំបូងចុចលើ Icon  នេះនៅស្តាំអេក្រង់ រួចចុចលើ Analysis Menu > Reinforcement Options





Tab General :




Tab Bottom Reinf :












Tab Transversal Reinf :





Tab Top Reinf :




Tab Constr Reinf :











Tab Shapes :




- នៅពេលកំណត់រួចរាល់ហើយចុចលើ Save As ..... វាយឈ្មោះ Euro code 1 រួចចុច ok ដើម្បីរក្សាទុក ។




៧-ចាប់ផ្តើមគណនារកសសៃវែក Start Calculate

- ដំបូងចុចលើ Icon  នេះនៅស្តាំអេក្រង់រឺចុចលើ Analysis Menu > Calculations……




ពេលនោះវានឹងបង្ហាញផ្ទាំង Calculation Option Set ដូចរូប



ជ្រើសរើសឈ្មោះត្រង់ Reinforcement parameters និង Calculation options ដែលយើងបានកំណត់រួចមក ហើយនៅចំនុចទី ៥ និង ទី៦ ខាងលើគឺឈ្មោះថា Euro code ។

-ករណីបើមាន Error & Warning វានឹងបង្ហាញផ្ទាំង Calculation Errors បន្ទាប់ពីចុច Calculation


-ករណីបើគ្មាន Error & Warning ទេវានឹងមិនបង្ហាញផ្ទាំង Calculation Errors



No.	Type	State	Span	x [m]	Value	Capacity	Safety Fac.
Beam1							
1	W [cm]	SLS	1	0.20	-0.83	-0.80	0.96
2	W [cm]	SLS	2	7.00	1.73	1.50	0.87
3	W [cm]	SLS	4	25.00	2.26	1.50	0.66
4	W [cm]	SLS	5	31.80	-1.65	-0.80	0.48


- W មានន័យថា Error ភាពដាប Deflection
- M មានន័យថា Error ម៉ូម៉ង់ Moment

- V មានន័យថា Error កំលាំងកាត់ទទឹង Shear force
- នៅពេល Program ប្រាប់ថា Error ត្រង់ណាហើយ យើងចុច ok ដើម្បីបិទផ្ទាំង Calculation Error បន្ទាប់មកត្រូវចុចទៅលើ Tab ULS ក្នុងតារាងខាងក្រោមដើម្បីមើលដ្យាក្រាម ម៉ូម៉ង់ កំលាំងកាត់ទទឹង និង ភាពដាប ដូចក្នុងរូបខាងក្រោម ។




ដ្យាក្រាម ម៉ូម៉ង់ និង កំលាំងកាត់ទទឹង


Moment and Shear force Diagram



ដ្យាក្រាម ភាពដាប
Deflection Diagram



ដ្យាក្រាម ដែក
Reinforcement Diagram




1- ULS : Diagram of Ultimate Limit State

www.yerngshare.blogspot.com


2- SLS : Diagram of Serviced Limit State
3- ALS : Diagram of Accidental Limit State
4- Area : Diagram of Longitudinal and Transversal Reinforcement
5- Deformations : Diagram of Beam Deflection
6- Simple Cases : Diagram of Simple Cases

៨- <u>ការត្រួតពិនិត្យមើលការដាក់រ៉ៀបចំសែសែក</u> <u>Beam – Reinforcement</u>

- ដំបូងចុចលើ Icon  នេះនៅស្តាំអេក្រង់រឺ ចុចលើ Layout ដូចរូប





បង្ហាញដូចរូប :



៩- កំណត់សំគាល់ការគណនា Calculation Note

- ដំបូងចុចលើ Icon  នេះនៅស្តាំអេក្រង់រឺ ចុចលើ Results Menu > Calculation Note







១០- Drawing Parameters


- ដំបូងចុចលើ Icon  នេះនៅស្តាំអេក្រង់រឺ ចុចលើ Analysis > Drawing Parameter

Tab General : ត្រង់កន្លែង Template ជ្រើសរើសយក ពាក្យថា bmbae05.plo សំរាប់មើល Drawing ទាំងមូល ។







Tab Reinforcement description : ត្រង់កន្លែង Number + diameter , Length , Spacing ជ្រើសរើសយកវាគឺដើម្បីអោយវាបង្ហាញ ចំនួនដែក មុខកាត់ដែក គំលាតដែក ។




Tab Scale : សំរាប់រៀបចំពណ៌ ទំហំបន្ទាត់ រៀបចំក្រដាស់ ..... ។




Tab Reinforcement table : សំរាប់អោយវាបង្ហាញចំនួន ដែក ទ្រង់ទ្រាយដែក ប្រភេទដែក.....។






១១- មើលប្លង់ Drawings

- ដំបូងចុចលើ Icon  នេះនៅស្តាំអេក្រង់រឺ ចុចលើ Results Menu > Drawings ដូចរូប







មេរៀនទី២

ការគណនាកំរាលប្តូចសេ

RC Slab Design


កំរាលប្តូចសេយកមកគណនា RC Slab Calculation :





3D View

- **<u>មុខកាត់គ្រឿងបន្ថំ</u>** <u>Frame Section :</u>



  - ការ៉ូ និង បាយអរ : 5cm (Mortar + Tile)
  - បង់សេកំរាស់ : 12cm (Slab)
  - បាយអរបូកពីដាន : 2cm (Plastering)

- **<u>កំណត់បន្ទុក</u>** <u>Determine loading :</u>

  - Weight of Tile f_t = 22kN/m^3
  - Weight of Mortar f_M = 22kN/m^3
  - Weight of Plastering f_p = 20kN/m^3
  - Weight of Concrete f_c = 25kN/m^3

- **<u>គណនាបន្ទុកក្នុង</u>** <u>1m^2 Calculate loading 1 m^2 :</u>

1. <u>Dead load :</u>
   - Mortar & Tile = 0.05m X 22kN/m^3 = 1.1kN/m^2
   - Plastering = 0.02m X 20kN/m^3 = 0.4kN/m^2
2. <u>Self weight :</u> (មិនចាំបាច់គណនាទេពិព្រោះ Program វាកំណត់ដោយខ្លួនវា)
   - Slab = 0.12m X 25kN/m^3 = 3kN/m^2
3. <u>Live load</u> : = 1.9kN/m^2


- **<u>សរុបបន្ទុក</u>** <u>Total load:</u>


  - Dead load : =1.5kN/m^2
  - Live load : =1.9kN/m^2

- <u>Analysis and Design យើងគណនាប្រើ:</u> ACI code
- <u>Material Properties for Analysis and Design យើងប្រើ Euro code :</u>


- Yield Strength of Longitudinal reinforcement : 400 MPa
- Yield Strength of Transversal reinforcement : 235 MPa
- Compressive Strength of Concrete (Cylinder) : 25 MPa
- Cover : 2cm

Step by Step Solution

នៅពេលបើក Program Autodesk Robot Structural Analysis Professional 2010 ដំបូងយើងនិងឃើញដូចរូបខាងក្រោមបន្ទាប់មកយើងជ្រើសរើសយក Icon  ដូចដែលបានបង្ហាញនៅលើរូបខាងក្រោម :




បន្ទាប់មកទៀតអេក្រង់នឹងបង្ហាញដូចរូបខាងក្រោមនេះ





- **បន្ទាប់មកចូរកំណត់** Units and Format, Materials and Codes មុនពេលធ្វើការ Analysis and Design :

ចុចលើ Tool Menu > Job Preference……




1. អេក្រង់នឹងបង្ហាញផ្ទាំងដូចរូប នៅត្រង់ Units and Formats ត្រូវកំណត់វាជា Metric រួច Yes






www.yerngshare.blogspot.com


2. នៅត្រង់ Materials ត្រូវកំណត់កូដអោយ Materials ត្រូវយកកូដ Euro code រួចចុចទៅលើ Modification ដើម្បីកំណត់ ។



3. រួចចុចលើ Tab Steel រួចត្រូវបំពេញ Name និង Description ដូចខាងក្រោម





4. រួចចុចលើ Tab Concrete រួចត្រូវបំពេញ Name និង Description និង Young modulus ដូចខាងក្រោម រួចចុច OK ។




www.yerngshare.blogspot.com

5. រួចចុចលើ Databases រួចរើសយក Reinforcing bars ហើយនៅប្រអប់ខាងស្តាំ ត្រូវបង្កើតកូដ BAEL99 ដោយចុចទៅលើ Icon ដែលមានឈ្មោះថា Add new databases to the list នោះវានឹងចេញតារាង Add Databases រួចរើសយក BAEL99 រួចចុច add ។ បន្ទាប់មករើសកូដដោយយក Mouse select on code រួចចុច Icon ដែលមានឈ្មោះថា Set as the current database ។






6. រួចចុចលើ Design codes ក្នុងប្រអប់ RC Structures ត្រូវកំណត់ជា ACI 318-08 metric




7. នៅត្រង់ Loads ក្នុងប្រអប់ Code combinations ត្រូវកំណត់ជា ACI318 រួចចុច OK ។




I. ការកំណត់ការគួរកំរាលប្លង់សេ

ដំបូងត្រូវចូល Polyline -Contour ហើយនៅត្រង់ Definition method ត្រូវយក Contour រួចនៅត្រង់ Geometry ត្រូវបំពេញដូចខាងក្រោម : បន្ទាប់មកត្រូវចុច Apply រួចចុច Close ។

កំរាលប្លង់សេ (x, y) ត្រូវចុច	កន្លែងជណ្តើរ (x, y) ត្រូវចុច
(0,0) រួចចុច add	(1,2) រួចចុច add
(6,0) រួចចុច add	(3,2) រួចចុច add
(6,4) រួចចុច add	(3,3) រួចចុច add
(0,4) រួចចុច add	(1,3) រួចចុច add
(0,0) រួចចុច add	(1,2) រួចចុច add







II. ការកំណត់កំរាស់កំរាលថ្ពង់សេ Slab Thickness

ដំបូងត្រូវចូល Panel រួចចូល New Thickness


Slab Thickness = 12cm រួចចុច add and close ។








បន្ទាប់ពីកំណត់កំរាស់ប្លង់សេរួចហើយ យើងចូលទៅចុច Reinforcement ដើម្បីរៀបចំដែកនឹងកូដ ។






នៅក្នុង Reinforcement មានដូចខាងក្រោម


- General
- Materials
- SLS Parameters
- Reinforcement

■ នោះវានឹងបង្ហាញតារាងដូចខាងក្រោម :


Tab General




Tab Materials



Tab SLS Parameters




Tab Reinforcement






\+ បង្កើត Coordinate




\+ Poly line


កំរាលប្លង់សេ (x, y) ត្រូវចុច		កន្លែងជណ្តើរ (x, y) ត្រូវចុច	
(0,0) រួចចុច Insert		(1,2) រួចចុច Insert	
(6,0) រួចចុច Insert		(3,2) រួចចុច Insert	
(6,4) រួចចុច Insert	រួចចុច Add	(3,3) រួចចុច Insert	រួចចុច Add
(0,4) រួចចុច Insert		(1,3) រួចចុច Insert	
(0,0) រួចចុច Insert		(1,2) រួចចុច Insert	


- បន្ទាប់ពីបំពេញរួចរាល់ហើយ ត្រូវយក Mouse មកដាក់នៅក្នុងប្រអប់ 

រួចត្រូវចុចនៅក្នុងប្លង់សេ (ដូចរូប) នោះប្លង់សេនឹងចាក់ហើយជាការស្រេច ។




- ការកំណត់ Grid Step Definition សំរាប់ Mesh ។ ដំបូងត្រូវចុច View Menu រួចចុចលើ Grid រួចចុចលើ Grid Step Definition ។(ដូចរូប)







IV ការកំណត់ទំរ និងការដាក់បន្ទុក Determine Supported :

- ដំបូងត្រូវចុចលើ Icon  នៅស្តាំអេក្រង់ ។ ត្រូវកំណត់បន្ទុកជា Fixed ដាក់ជុំវិញកំរាលបួងសេ ត្រូវកំណត់វាជា Linear គឺត្រូវដាក់ Mouse នៅក្នុងប្រអប់ Current Selection រួចយកទៅ Select លើគែមបួងសេទាំងបួនទិស ទាល់តែវាចេញ ពណ៌ខៀវចាំ Select វាជាក្រោយ ។






- បន្ទាប់ពីដាក់បន្ទុករួច វានឹងចេញរូបដូចខាងក្រោម : ជុំវិញវាមានបន្ទាត់ពន្លឺជុំវិញវា ។(ដូចរូប)



V បង្កើតប្រភេទបន្ទុក (Load Types) ៖

- ដំបូងត្រូវជ្រើសរើសបន្ទុកនៅកន្លែង Nature រួចដាក់ឈ្មោះនៅកន្លែង Name រួចចុច New ។ បញ្ជាក់បើ Nature រើសជាអ្វីនោះ នៅត្រង់ Name ត្រូវដាក់ឈ្មោះដូចនោះដែល ។ (ដូចរូប)




Nature : dead
Name : DL1 New

Nature : live
Name : LL1 New

Nature : dead
Name : Self- weight New


VI កំណត់ការដាក់បន្ទុកលើកំរាលច្រង់សេ (Apply Loads) ៖


~ ដំបូងត្រូវចុចលើ Icon  នៅខាងស្តាំអេក្រង់ ។ បើដាក់ Dead Load គឺត្រូវរើស DL1 នៅក្នុងប្រអប់ខាងលើដូចរូប




- បន្ទាប់មកត្រូវចុចលើ Surface រួចចុចលើ Icon  ដូចរូប ។ បន្ទាប់មកត្រូវបញ្ចូល Dead Load គឺ Z = -1.5 វាយសញ្ញាដកគឺបញ្ជាក់ថាទិសដៅចុះក្រោម ។ រួចចុច add រួចដាក់ Mouse នៅក្នុងប្រអប់ Apply to រួចយក មកចុះលើបង្ហង់សេ រួចចុច Apply and close នោះជាការស្រេច ។ បន្ទាប់មកដាក់ Live Load ក៏ដូចនោះដែល ។


- ការដាក់បន្ទុក Dead Loads គឺ Z = -1.5kN/m^2






- ការដាក់បន្ទុក Live Load គឺ Z = -1.9kN/m^2






បន្ទុកអចេរ DL




បន្ទុកថេរ LL


VII **ការបន្សុំបន្ទុក** (Combination Loads) ៖

- ដំបូងចុចលើ Icon  នេះនៅខាងស្តាំអេក្រង់ ។ ត្រង់ប្រអប់ Combination Name: ត្រូវវាយ ULS ដើម្បីមើលម៉ូម៉ង់សរុបទាំងមូល ។ រួចចុច ok នោះវានឹងចេញផ្ទាំង Combination ដូចខាងក្រោម ៖






- រួចត្រូវបោះតំលៃនៅប្រអប់ខាងឆ្វេងទៅខាងស្តាំទាំងអស់ដោយចុចសញ្ញានេះ  បន្ទាប់មកវានឹងចេញផ្ទាំងដូចខាងក្រោម




- តាមតារាងខាងលើនេះ យើងឃើញថាតំលៃបន្ទុកទាំងអស់គឺខុសទាំងអស់ ដូចនេះយើងត្រូវធ្វើការផ្លាស់ប្តូរដោយចុចសញ្ញានេះ << ឱ្យវាមកចូលក្នុងតារាងខាងឆ្វេងវិញ ដូចរូប រួចចុចពាក្យ Factor definition នោះវានឹងចេញតារាងមួយទៀតគឺ Combination Factors ដូចរូប ។





~ បន្ទាប់មកត្រង់កន្លែង Factor: ត្រូវវាយតំលៃលេខចូល ទៅតាមបន្ទុក ហើយត្រូវឱ្យសញ្ញាព្រួញដាក់ឱ្យចំបន្ទុកដែលយើងចង់ដាក់ រួចចុច Change ជាការស្រេច ។ បន្ទុកផ្សេងៗទៀតធ្វើការកែដូចគ្នា ។ មើលរូប


មិនទាន់ផ្លាស់ប្តូរ




ផ្លាស់ប្តូររួច







តារាងដែលកែរួច
ហើយបោះទៅខាងស្តាំ
រួចចុច Apply and Close.




VIII ការ Mesh កំរាលថ្នង់សេ :

- ដំបូងចុចលើរូប  នៅខាងលើអេក្រង់ បន្ទាប់មកចុចលើរូប 




- រចុចលើ Analysis Menu > Calculation Model > Meshing Options…….




-បន្ទាប់មកដើម្បីបានតារាងខាងក្រោមយើងត្រូវចុចនៅក្នុង

តារាង Meshing Option


ដោយចុចត្រង់ពាក្យ Advanced Option




នោះនឹងបានតារាងដូចខាងក្រោម រួចចុច ok



- ធ្វើការ Mesh កំរាលបង្អែសេ
- ដោយចុចលើរូប 




- រូបភាពក្រោយពីធ្វើការ Mesh រួច




IX ការគណនាកំរាលបង្អែសេ :

-ដំបូងចុចលើរូប Icon  នេះនៅខាងលើអេក្រង់ ដើម្បីគណនារកកំលាំងក្នុងកំរាលបង្អែសេ ។ នោះនឹងចេញផ្ទាំងដូចខាងក្រោម ។ តែបើតារាងនេះចេញមួយភ្លែត ហើយរលត់ទៅវិញនោះមានន័យថា ការធ្វើការគណនារបស់យើងបានល្អ ។ តែផ្ទុយទៅវិញ បើចេញនៅគាំងស្ងៀញ មានន័យថាការគណនារបស់យើងមិនបានល្អ ។




~ ការមើលលទ្ធផល Result – maps


-ចុចលើ Layout រួចរើសយក Result-maps




នោះវានឹងចេញតារាងដូចខាងក្រោម :




រូបភាពបន្ទាប់ពីចុច Apply ខាងលើ





Reinforcements
Reinforcement
SLS
Scale
X [-] Y [-] X [+] Y [+]
Required reinforcement:
Area A
Spacing e
Number of bars n
Minimum reinforcement:
Area A
Spacing e
Number of bars n
Cross presentation:
(+) top
(-) bottom
description starts with:
reinforcement areas
cm2
reinforcement spacing
cm
smoothing within a panel
Isolines
Maps
Values
With normalization
With FE mesh
With description
Open new window with scale displayed
Apply
Close
Help


Reinforcements
Reinforcement
SLS
Scale
X [-] Y [-] X [+] Y [+]
Cracking a
Stiffness factor
Deflection u
smoothing within a panel
Isolines
Maps
Values
With normalization
With FE mesh
With description
Open new window with scale displayed
Apply
Close
Help



Reinforcements
Reinforcement
SLS
Scale
Color palette:
Automatic scale
0.00
0.00
0.00
0.00
0.00
Scale type selection:
Linear scale
0.5
User limits:
Max :
1.4305e-24
(cm2/m)
Division:
Min :
2.60988e-3
(cm2/m)
13
Isoline thickness:
1
Open
Save
Normalize
smoothing within a panel
Isolines
Maps
Values
With normalization
With FE mesh
With description
Open new window with scale displayed
Apply
Close
Help

X ការកំណត់សសៃចែក :

1- ដំបូងចូល Analysis រួចចូល Design of RC Structure elements រួចចូល RC Panel Design រួចចូល Provided Reinforcement ។ រួចចូល Icon នេះ  នៅខាងស្តាំដៃ ។





បន្ទាប់ពីចុចលើពាក្យ Provided Reinforcement



2- ការកំណត់ Story Parameters


ដំបូងចុចលើ Icon  នេះនៅខាងស្តាំអេក្រង់ រឺ ចុចលើ Analysis Menu > Story Parameters








3- ការកំណត់ Calculation Options :


ដំបូងចុចលើ Icon  នេះនៅខាងស្តាំអេក្រង់ រឺ ចុចលើ Analysis Menu > Calculation Option




Calculation Options - ACI 318-08 metric; Regulation - ACI318
General
Concrete
Reinforcing bars
Wire fabrics
Reinf. for punching
Materials:
Eurocode
Name:
C25/30
Characteristic strength:
25.00
MPa
Unit weight:
2501.36
kG/m3
Aggregate size:
20.3
mm
Sand percentage
0
(%)
Aggregate type:
Siliceous
OK
Cancel
Help
Standard
Save As ...
Delete



Calculation Options - ACI 318-08 metric; Regulation - ACI318
General
Concrete
Reinforcing bars
Wire fabrics
Reinf. for punching
Steel:
BAEL 99
Grade:
HA 400
Deformed
Characteristic strength
400.00
(MPa)
Name
d (mm)
A (cm2)
1 5 5.0 0.20
2 6 6.0 0.28
3 8 8.0 0.50
4 10 10.0 0.79
5 12 12.0 1.13
6 14 14.0 1.54
7 16 16.0 2.01
8 20 20.0 3.14
9 25 25.0 4.91
10 32 32.0 8.04
11 40 40.0 12.57
OK
Cancel
Help
Standard1
Save As ...
Delete








4- ការកំណត់ Reinforcement Pattern :


ដំបូងចុចលើ Icon  នេះនៅខាងស្តាំអេក្រង់ រឺ ចុចលើ Analysis Menu > Reinforcement Option







Reinforcement Pattern - ACI 318-08 metric
General
Bars
Wire fabric reinf.
Constructional reinf.
Shapes
Wire fabric: horizontal division
Theoretical length
1/5
1/4
1/3
1/2
2/3
3/4
4/5
1
Wire fabric: vertical division
Theoretical length
1/5
1/4
1/3
1/2
2/3
3/4
4/5
1
Reutilization of cut-offs
Min. area:
1.00
m2
Min. dimension:
0.50
m
2 different panels allowable
Openings
Apply for L <=
0.15
m
Panel location
According to X direction
According to Y direction
Reinforcement type
OK
Cancel
Help
Standard
Save As ...
Delete


Reinforcement Pattern - ACI 318-08 metric
General
Bars
Wire fabric reinf.
Constructional reinf.
Shapes
Opening corners reinforcement
Bar diameter:
Auto
Number of insets:
2
Length of inset arm:
l=
0.60
m
Openings ignored:
l <=
0.50
m
Reinforcement of beam supports
e
d
d
e
0.10
m
OK
Cancel
Help
Standard
Save As ...
Delete




XI- ចាប់ផ្តើមគណនារកសរសៃដែក Start Calculate Provided Reinforcement :

ដំបូងចុចលើ Icon  នេះនៅខាងស្តាំអេក្រង់ រឺ ចុចលើ Analysis Menu > Reinforcement Option




ពេលនោះវានឹងបង្ហាញផ្ទាំង Calculation Option Set




ជ្រើសរើសឈ្មោះត្រង់ Reinforcement parameters និង Calculation options ដែលយើងបានកំណត់រួចមក ។ រួចចុច Calculations .

បន្ទាប់ពីចុច Calculation រួច ។





XII ការត្រួតពិនិត្យមើលការដាក់សរសៃដែក Slab-Reinforcement

-ដំបូងចុចលើ Layout រើសយក Slab-reinforcement




បង្ហាញដូចរូប





ការបង្ហាញមើលម៉ូម៉ង់ : ដំបូងត្រូវកែខាងលើយក Results-maps 


រួចយក Mouse ទៅចុចលើ Icon  នេះនៅខាងស្តាំអេក្រង់ នឹងចេញផ្ទាំងដូចខាងក្រោម




រួចចូល Definition ហើយចុចយក Parallel to axis X រួចដាក់ Mouse នៅក្នុងប្រអប់ក្រោមវា រួចចុច Apply រួចយកមកចុចនៅលើ Slab តាមទិស X ។ ដូចរូប










បន្ទាប់មកចូល Diagrams ចុចត្រង់ Labels និង Normal រួចចុច Apply ដើម្បីមើល Diagrams វា ។ ដូចរូប





រួចចូលតាមទិស Y ដូចរូប







XIII Calculation – Note


www.yerngshare.blogspot.com

ដំបូងចុចលើ Icon  នេះនៅខាងស្តាំអេក្រង់ រឺ ចុចលើ Analysis Menu > Calculation– Note







បន្ទាប់ពីចុច OK វានឹងចេញផ្ទាំងពត៌មានដូចខាងក្រោម





XIV Drawing Parameters


ដំបូងចុចលើ Icon  នេះនៅខាងស្តាំអេក្រង់ រឺ ចុចលើ Analysis Menu > Drawing Parameters













Drawing Parameters
General
Reinforcement description
Scale
Reinforcement table
The same for all pages
The same for elevation and section
The same for both directions on elevation
User scale
Elevation:
1 :
20
Adjust
Section:
1 :
20
Adjust
Notation
1 : n
n cm = 1m
1:20
1:20
1:20
1:20
Thickness of lines (mm)
0.10
0.50
0.30
0.10
OK
Cancel
Help
Set as default
Restore default


Drawing Parameters
General
Reinforcement description
Scale
Reinforcement table
Bar number
Shape code
Number
Shape
Steel type
Bar diameter symbol
Description of deformed steel
{%sym}{%dia} {%stl} {%cod}
Description of plain steel
{%sym}{%dia} {%stl} {%cod}
Grouping of bars
Global - common for all elements in the project
Local - independently for each element in the project
In numbering, consider that an element belongs to:
Spans
Type
Bars numbered individually
OK
Cancel
Help
Set as default
Restore default

XV មើលប្លង់ Drawing

ដំបូងចុចលើ Icon  នេះនៅខាងស្តាំអេក្រង់ រឺ ចុចលើ Result Menu > Drawings






មេរៀនទី៣


ការគណនាសសរ


RC Column Design

សសរបេតុងអារមេយកមកគណនា RC Column Calculation :



Plan View






3D View

- **<u>មុខកាត់គ្រឿងបន្ថំ</u>** <u>Frame Section :</u>
  - ការ៉ូ បាយអរ និង ប្លង់សេ : 12cm (Tile + Mortar + Slab)
  - កំពស់ធ្នឹម : 30cm (Beam)
  - មុខកាត់សសរ h = 30cm , h = 30cm (Column Section)
  - កំពស់សសរ L = 4m (Column height)
- **<u>ការកំណត់ប្រភេទបន្ទុក</u>** <u>Determine loading :</u>
  - Dead load អោយតំលៃ : N = 360.0kN , Fy = 0.0 , My = 50.0 , M_Z = 10.0
  - Live load អោយតំលៃ : N = 120.0kN , Fy = 0.0 , My = 25.0 , M_Z = 3.0
- <u>Analysis and Design ដោយ :</u> ACI code
- <u>Material Properties for Analysis and Design :</u>


- Yield Strength of Longitudinal Reinforcement : 390 MPa
- Yield Strength of Transversal Reinforcement : 235 MPa
- Compressive Strength of Concrete (Cylinder) : 25 MPa

Step by Step Solution

នៅពេលបើក Program Autodesk Robot Structural Analysis Professional 2010 ដំបូងយើងនិងឃើញដូចរូបខាងក្រោមបន្ទាប់មកយើងជ្រើសរើសយក Icon  ដូចដែលបានបង្ហាញនៅលើរូបខាងក្រោម :




បន្ទាប់មកទៀតអេក្រង់នឹងបង្ហាញដូចរូបខាងក្រោមនេះ





បន្ទាប់មកចូរកំណត់ Units and Format, Materials and Codes មុនពេលធ្វើការ Analysis and Design :

I. ចុចលើ Tool Menu > Job Preference……




1. អេក្រង់នឹងបង្ហាញផ្ទាំងដូចរូប នៅត្រង់ Units and Formats ត្រូវកំណត់វាជា Metric រួច Yes







2. នៅត្រង់ Materials ត្រូវកំណត់កូដអោយ Materials ត្រូវយកកូដ Euro code រួចចុចទៅលើ Modification ដើម្បីកំណត់ ។




3. រួចចុចលើ Tab Steel រួចត្រូវបំពេញ Name និង Description ដូចខាងក្រោម




4. រួចចុចលើ Tab Concrete រួចត្រូវបំពេញ Name និង Description និង Young modulus ដូចខាងក្រោម រួចចុច OK ។




5. រួចចុចលើ Databases រួចរើសយក Reinforcing bars ហើយនៅប្រអប់ខាងស្តាំ ត្រូវបង្កើតកូដ BAEL99 ដោយចុចទៅលើ Icon ដែលមានឈ្មោះថា Add new databases to the list នោះវានឹងចេញតារាង Add Databases រួចរើសយក BAEL99 រួចចុច add ។ បន្ទាប់មករើសកូដដោយយក Mouse select on code រួចចុច Icon ដែលមានឈ្មោះថា Set as the current database ។






6. រួចចុចលើ Design codes ក្នុងប្រអប់ RC Structures ត្រូវកំណត់ជា ACI 318-08 metric




7. នៅត្រង់ Loads ក្នុងប្រអប់ Code combinations ត្រូវកំណត់ជា ACI318 រួចចុច OK ។



I. **ការកំណត់ចុះកាត់សសរ** (Column Section)

ដំបូងត្រូវវាយបញ្ចូលតំលៃមុខកាត់សសរ និងរើសមុខកាត់សសរនៅក្នុងតារាង Section ហើយនៅត្រង់ Label ត្រូវវាយ CR30X30 រួចនៅត្រង់ b និង h ត្រូវវាយតំលៃបញ្ចូល b=30 និង h=30 រួចចុច ok នោះយើងនឹងបានមុខកាត់សសរ ។





II. **ការកំណត់** Elevation Dimensions :

ដំបូងត្រូវចុចលើ Icon  នៅខាងស្តាំងអេក្រង់ រឺចុចលើ Structure Menu > Dimensions…….



នោះនឹងចេញតារាងដូចខាងក្រោម :






ក្នុងប្រអប់ Elevation Dimension វាយតំលៃ L=4 ជាកំពស់សសរ , Hb=0.42 ជាកំពស់ធ្នឹម និង ប្លង់សេ , Hp=0.12 ជាកំពស់ប្លង់សេ រួចចុច ok ។

III. ការកំណត់ប្រវែងភ្ជាត់ Buckling Length


ដំបូងត្រូវចុចលើ Icon  នេះនៅខាងស្តាំងអេក្រង់ រឺចុចលើ Structure > Buckling Length .....




នោះនឹងចេញផ្ទាំងដូចខាងក្រោម : បន្ទាប់មកគ្រាន់តែពិនិត្យមើល



តំលៃមេគុណ k រួចចុច Save As រួចចុច Close ។






IV. ការកំណត់ប្រភេទបន្ទុក Load Definition


ដំបូងត្រូវចុចលើ Icon  នេះនៅខាងស្តាំងអេក្រង់ រឺចុចលើ Structure > Load .....



នោះនឹងចេញផ្ទាំងដូចខាងក្រោម : បន្ទាប់មកគ្រាន់តែវាយតំលៃបន្ទុក




ដែលមាន អំពើលើសសរ រួចចុច ok ។




V. ការកំណត់ Story Parameters

ដំបូងត្រូវចុចលើ Icon  នេះនៅខាងស្តាំងអេក្រង់ រឺចុចលើ Analysis > Story Parameters ..... នោះនឹងចេញផ្ទាំងដូចខាងក្រោម : បន្ទាប់មកគ្រាន់តែវាយតំលៃ



Reference Level = 4 រួចចុច ok ។





VI. ការកំណត់ Calculation Options

នៅក្នុង Calculation Option មាន ៤ Tab ដែលត្រូវកំណត់


- Tab General : កំណត់ស្រទាប់ការពារ គិតពីប្រវែងសសរចូលគណនា និងការកំណត់ផ្សេងទៀត.....
- Tab Concrete : កំណត់រ៉ែស៊ីស្តង់ សង្កត់របស់បេតុងនៅអាយុ២៨ថ្ងៃ
- Tab Longitudinal reinf : កំណត់រ៉ែស៊ីស្តង់ដែកបណ្តោយ និងអង្កត់ផ្ចិត
- Tab Transversal reinf : កំណត់រ៉ែស៊ីស្តង់ដែកកង និងអង្កត់ផ្ចិត

ដំបូងចុចលើ Icon  នេះនៅខាងស្តាំងអេក្រង់ រឺចុចលើ Analysis Menu > Calculation Option ..... នោះនឹងចេញផ្ទាំងដូចខាងក្រោម : Tab General







Tab Concrete :



Tab Longitudinal reinf…..



Tab Transversal reinf…..



នៅពេលកំណត់រួចរាល់ហើយត្រូវចុចលើ Save As វាឈ្មោះ ACI រួចចុច ok ដើម្បីរក្សាទុក ។


VII. **ការកំណត់** Reinforcement Pattern

នៅក្នុង Reinforcement Pattern មាន ៤ Tab ដែលត្រូវកំណត់

- Tab Longitudinal bars : កំណត់គំលាតពីសសៃដែក១ទៅសសៃដែក១ ការចងដែក……
- Tab Transversal bars : កំណត់គំលាតចងដែកកង និងការពត់ដែកកង ……
- Tab Dowel bars : កំណត់ប្រវែងដែកសំរាប់ទុកអោយតភ្ជាប់ទៅសសរខាងលើ……
- Tab Shapes : កំណត់ទ្រង់ទ្រាយ លក្ខណៈនៃការចងដែក……


ដំបូងចុចលើ Icon  នេះនៅខាងស្តាំអេក្រង់ រីចុចលើ Analysis Menu > Reinforcement Options …….

នោះនឹងចេញផ្ទាំងដូចខាងក្រោម :







Tab Longitudinal bars:



